ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក
និងអាហ្វ្រិក-មជ្ឈិមបូព៌ា
នាយកដ្ឋានអឺរ៉ុប

សេចក្ដីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី២រវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឆែក

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ - **ឯកឧត្តមបណ្ឌិត ថែម វីឡា** រដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម** Jiří Kozák អនុរដ្ឋមន្ត្រីការបរទេស នៃក្រសួងការបរទេសនៃសាធារណរដ្ឋឆែក បានធ្វើជាសហប្រធាននៃកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី២ រវាងប្រទេសទាំងពីរ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ភាគីទាំងពីរបានកត់សម្គាល់ ដោយសេចក្ដីពេញចិត្តចំពោះចំណងមិត្តភាពដ៏ល្អប្រសើរជាប្រពៃណី និងកិច្ចសហប្រតិបត្តិការដែលកំពុងលូតលាស់រវាងប្រទេសទាំងពីរ។ ឯកឧត្តមទាំងពីរបានបង្ហាញការប្ដេជ្ញាចិត្តក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយដែលជាផលប្រយោជន៍រួម ឱ្យកាន់តែប្រសើរថែមទៀត។

**ឯកឧត្តមបណ្ឌិត ថែម វីឡា** បានសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ជូនចំពោះរដ្ឋាភិបាល និងប្រជាជនឆែក ចំពោះជំនួយសប្បុរសធម៌ជាច្រើនឆ្នាំកន្លងមក ចាប់តាំងពីការរំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានរួមចំណែកយ៉ាងសំខាន់ទៅដល់សុខុមាលភាព និងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ **ឯកឧត្តមបណ្ឌិតរដ្ឋលេខាធិការ** ក៏បានសង្ខេបជូនសមភាគីឆែកអំពីស្ថានភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាផងដែរ។

អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

**ឯកឧត្តម Jiří Kozák** បានស្ងើចសរសើរការកើនឡើងយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជា ការធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២ និងការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ ប្រកបដោយភាពជោគជ័យ។ ឯកឧត្តមក៏បានបញ្ជាក់ផងដែរថា កត្តាស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចប្រកបដោយថាមវន្តរបស់កម្ពុជា បានជំរុញឱ្យអ្នកវិនិយោគឆែកចាប់អារម្មណ៍មកវិនិយោគនៅកម្ពុជា។

ក្នុងអំឡុងកិច្ចពិភាក្សា ភាគីទាំងពីរបានពិនិត្យឡើងវិញនូវគម្រោងកិច្ចសហប្រតិបត្តិការដែលមានស្រាប់។ ឯកឧត្តមទាំងពីរបានផ្លាស់ប្តូរយោបល់អំពីមធ្យោបាយនានាដើម្បីលើកកម្ពស់ទំនាក់ទំនងទ្វេភាគីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទៅជាភាពជាដៃគូដ៏រឹងមាំ។ ឯកឧត្តមទាំងពីរបានគូសបញ្ជាក់ពីវិស័យអាទិភាពចំបង រួមមានវិស័យសុខាភិបាល និងអប់រំ។ ប្រធានបទនៃកិច្ចពិភាក្សាផ្សេងទៀតរួមមាន វិស័យពាណិជ្ជកម្ម និងវិនិយោគ វប្បធម៌ ទេសចរណ៍ ការដឹកជញ្ជូនផ្លូវអាកាស ថាមពលកកើតឡើងវិញ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា កសិកម្ម និងអភិវឌ្ឍន៍ជនបទ-ល-។ ភាគីទាំងពីរក៏បានឯកភាពលើកទឹកចិត្តតួអង្គពាក់ព័ន្ធធ្វើការរួមគ្នា ដើម្បីបង្កើតឯកសារគតិយុត្តិ និងរៀបចំវេទិកាវិនិយោគ និងធុរកិច្ចជាទៀតទាត់នៅក្នុងប្រទេសទាំងពីរ ដើម្បីទទួលបានការចូលរួមកាន់តែសកម្មពីវិស័យឯកជន។

ភាគីទាំងពីរបានចែករំលែកទស្សនៈគ្នាទៅវិញទៅមកលើបញ្ហាតំបន់ និងពិភពលោកដែលជាផលប្រយោជន៍ និងកង្វល់រួមមួយចំនួន ដែលក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិតរដ្ឋលេខាធិការ** កោតសរសើរការចូលរួមយ៉ាងសកម្មរបស់ឆែកក្នុងពេលធ្វើជាប្រធានគណៈកម្មការសហភាពអឺរ៉ុបនៅពាក់កណ្តាលឆ្នាំ ២០២២ នៅក្នុងគោលគំនិតឥណ្ឌូ-ប៉ាស៊ីហ្វិករបស់សហភាពអឺរ៉ុប និងក្នុងការរួមចំណែកដ៏សំខាន់របស់សាធារណរដ្ឋឆែក ដែលបានរៀបចំកិច្ចប្រជុំកំពូលដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៤៥ ភាពជាដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុបនៅទីក្រុងព្រុចសែលប្រកបដោយជោគជ័យកាលពីខែធ្នូ ឆ្នាំ២០២២។

ជាទីបញ្ចប់នៃកិច្ចពិភាក្សា ភាគីទាំងពីរបានបង្ហាញចំណាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងការបន្តកិច្ចសន្ទនាតាមរយៈកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសទាំងពីរ ដែលជាយន្តការមានប្រសិទ្ធភាពសម្រាប់តាមដានសកម្មភាពដែលបានឯកភាពកន្លងមក ដើម្បីធ្វើឱ្យទំនាក់ទំនងទ្វេភាគីលើគ្រប់វិស័យកាន់តែស៊ីជម្រៅ។ កិច្ចប្រជុំបានប្រព្រឹត្តទៅដោយជោគជ័យក្នុងបរិយាកាសស្និទ្ធស្នាល និងប្រកបដោយផ្លែផ្កា។ កិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងកម្ពុជា និងសាធារណរដ្ឋឆែកលើកទី៣ នឹងត្រូវធ្វើឡើងនៅសាធារណរដ្ឋឆែក៕